ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ៣៥ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្ដាហ៍

ក

មាតិកា

I-ទីស្តីការគណៈរដ្ឋមន្ត្រី

អនុក្រឹត្យ

២៧_៩_១៩៩៥ អនុក្រឹត្យលេខ ៧០ អនក្រ. បក ស្តីពីការបង្កើតគណៈកម្មការជាតិកំចាត់ជម្ងឺរបេង ១៨១៣

២៧_៩_១៩៩៥ អនុក្រឹត្យលេខ ៧១ អនក្រ. បក ស្តីពីការបង្កើតគណកម្មការជាតិសំរាប់បង្ការទប់ស្កាត់ និងបន្ថយជម្ងឺអេដស៍ និងជម្ងឺកាមរោគ ១៨១៦

៣០_៩_១៩៩៥ អនុក្រឹត្យលេខ ៧២ អនក្រ. បក ស្តីពីការកែសំរួលនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និងជលសាស្ត្រអោយទៅអគ្គនាយកដ្ឋានធារាសាស្ត្រឧតុនិយម និងជលសាស្ត្រ ១៨១៩

២៧_៩_១៩៩៥ អនុក្រឹត្យលេខ ១០៩ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៨២២

២៧_៩_១៩៩៥ អនុក្រឹត្យលេខ ១១០ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៨២៣

II-ការខារបណ្ណាក្រសួង

១_ទីស្តីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាស

២៨_៩_១៩៩៥ ប្រកាសលេខ ១៣២ សហវ. ប្រក. ប ស្តីពីការកែតំរូវការដាក់មន្ត្រីរាជការចូលនិវត្តន៍ ០២ រូប ដោយអនុញ្ញាតអោយបន្តការងារវិញ ១៨២៥

៣០–៩–១៩៩៥ ប្រកាសលេខ ៣២៨ ប្រក. សហវ. ថ ស្តីពីការបង្វែឥណទាន ១៨២៦

២_ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

ប្រកាស

២៦_៩_១៩៩៥	ប្រកាសលេខ ១៥០៧ អយក.ប្រក ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សាមិត្តភាព មកជាសាលាបឋមសិក្សា «សម្តេចជាស៊ីម»	១៨២៨

៣_ទីស្តីការរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

២៨_៩_១៩៩៥	ប្រកាសលេខ ១៦២ ប្រកវវស.បុ ស្តីពីការលុបឈ្មោះមន្ត្រីរាជការមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកណ្តាល	១៨៣០
២៨_៩_១៩៩៥	ប្រកាសលេខ ១៦៣ ប្រក.វវស.បុ ស្តីពីការលុបឈ្មោះមន្ត្រីរាជការមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តព្រៃវែង	១៨៣១
២៩_៩_១៩៩៥	ប្រកាសលេខ ១៦៤ ប្រក.វវស.បុ ស្តីពីការបញ្ចូលក្របខ័ណ្ឌមន្ត្រីរាជការនៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តកំពង់ស្ពឺ	១៨៣៣
៣០_៩_១៩៩៥	ប្រកាសលេខ ១៦៥ ប្រក.វវស.បុ ស្តីពីការលុបឈ្មោះមន្ត្រីរាជការមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តកណ្តាល	១៨៣៤

៤_ទីស្តីការ ក្រសួងធម្មការ និងសាសនា

ប្រកាស

២៨_៩_១៩៩៥	ប្រកាសលេខ ១៩៤/៩៥ កធស.ប្រក ស្តីពីការលុបឈ្មោះមន្ត្រីរាជការ	១៨៣៦
២៨_៩_១៩៩៥	ប្រកាសលេខ ១៩៥/៩៥ កធស.ប្រក ស្តីពីការលុបឈ្មោះមន្ត្រីរាជការ	១៨៣៧
២៩_៩_១៩៩៥	ប្រកាសលេខ ២០០/៩៥ កធស ស្តីពីការទទួលស្គាល់គណកម្មាធិការប្រិយសម្ព័ន្ធគ្រិស្តបរិស័ទនៅកម្ពុជា	

៥_រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ប្រកាស

២៧_៩_១៩៩៥ ប្រកាសលេខ ១០០២ មស.បល ស្តីពីការបញ្ចូលក្របខ័ណ្ឌពេញសិទ្ធិ ១៣៣៩

៦_រដ្ឋលេខាធិការដ្ឋានកិច្ចការនារី

ប្រកាស

២៩_៩_១៩៩៥ ប្រកាសលេខ ៨៣៨ រកន ស្តីពីការផ្ទេរមន្ត្រីរាជការ ១៨៤០

I-ទីស្តីការគណៈរដ្ឋមន្ត្រី

អនុក្រឹត្យ

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៧០ អនក្រ.បក

ស្តីពី

ការបង្កើតគណៈកម្មការជាតិ កំចាត់ជំងឺរបេង

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ។
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល ។
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សំរេច

មាត្រា ១ :បង្កើតគណៈកម្មការជាតិមួយឈ្មោះថា គណៈកម្មការជាតិកំចាត់ជំងឺរបេង ដែលមានសមាសភាពដូចខាងក្រោម :

១- សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីទី ២ ប្រធានកិត្តិយស

២– ឯកឧត្តម **ឈា ថាំង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រធាន

៣– ឯកឧត្តម **ឌី ណារ៉ុងរិទ្ធិ** រដ្ឋលេខាធិការក្រសួងសុខាភិបាល អនុប្រធាន

៤– ឯកឧត្តម អនុរដ្ឋលេខាធិការក្រសួងពត៌មាន សមាជិក

៥– ឯកឧត្តម អនុរដ្ឋលេខាធិការក្រសួងអប់រំ សមាជិក

៦– ឯកឧត្តម អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

៧– ឯកឧត្តម អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៨– លោក អភិបាលរងរាជធានីភ្នំពេញ និងខេត្ត ក្រុង សមាជិក

មាត្រា ២: គណៈកម្មការជាតិកំចាត់ជំងឺរបេង មានលេខាធិការដ្ឋានជាជំនួយការ ដែលមានសមាសភាពដូចខាងក្រោម :

១– លោកវេជ្ជបណ្ឌិត **គង់ គឹមសាន**	ប្រធានកម្មវិធីជាតិជំងឺរបេង	ប្រធាន
២– លោកវេជ្ជបណ្ឌិត**ខូច សារ៉េត**	អនុប្រធានកម្មវិធីជាតិជំងឺរបេង	អនុប្រធាន
៣– លោកឱសថការី **សេង លីមនៅ**	ប្រធាននាយកដ្ឋានគ្រប់គ្រងឱសថ	សមាជិក
៤– លោកវេជ្ជបណ្ឌិត **នា វណ្ណា**	ប្រធានកម្មវិធីអេដស៍	សមាជិក
៥–លោកវេជ្ជបណ្ឌិត **ច ម៉េងជូ**	ប្រធានអង្គភាពផែនការ ឬតំណាង	សមាជិក
៦– លោកស្រីឱសថការី **គាត តួច**	ប្រធានការិយាល័យបច្ចេកទេស នៃកម្មវិធីជាតិជំងឺរបេង	សមាជិក
៧– លោកវេជ្ជបណ្ឌិត **នាម បាក់ឃីម**	អនុប្រធានការិយាល័យបច្ចេកទេសនៃ កម្មវិធីជាតិជំងឺរបេង	សមាជិក

មាត្រា ៣ : គណៈកម្មការជាតិកំចាត់ជំងឺរបេង មានភារកិច្ច :

–វាយតំលៃ និងតំរង់ទិសកម្មវិធីជាតិកំចាត់រោគរបេង ។

–ពង្រីកទំនាក់ទំនង និងសហប្រតិបត្តិការជាមួយអង្គការជាតិ អន្តរជាតិនានា ទាំងក្នុ

រដ្ឋាភិបាល និងក្រៅរដ្ឋាភិបាល អង្គការមហាជន និងសមាគមនានា ដើម្បីជួយទ្រទ្រង់កម្មវិធីទាំងបច្ចេកទេស និងថវិកា ។

-លើកយោបល់ជូនរាជរដ្ឋាភិបាល នូវបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងកម្មវិធី ដើម្បីដោះស្រាយអោយទាន់ពេលវេលា ។

-ធ្វើរបាយការណ៍អំពីលទ្ធផលដែលបានអនុវត្តជូនរាជរដ្ឋាភិបាល ។

លេខាធិការដ្ឋានមានភារកិច្ច :

-លើកកំពស់គុណភាព ប្រសិទ្ធភាពការងារបច្ចេកទេសស្រាវជ្រាវ ព្យាបាល ការងារតាមដានអ្នកជំងឺរហូតជាសះស្បើយ ការងារគ្រប់គ្រង និងផ្គត់ផ្គង់ឱសថអោយបានដល់ដៃអ្នកជំងឺ ។

-ខិតខំជំរុញសកម្មភាពឃោសនា អប់រំផ្សព្វផ្សាយ ជូនប្រជាពលរដ្ឋតាមប្រព័ន្ធឃោសនា និងសារពត៌មាន ។

- ខិតខំអនុវត្ត រាល់គោលដៅដែលកម្មវិធីបានដាក់ចុះ ។

មាត្រា ៤ : គណៈកម្មការជាតិកំចាត់ជំងឺរបេង នឹងជួបប្រជុំការងារយ៉ាងតិចមួយឆ្នាំម្តង ។

មាត្រា ៥ : គណៈកម្មការជាតិកំចាត់ជំងឺរបេង អាចរួមបញ្ចូលសមាជិក សហការងារចំពោះអ្នកដែលបានជួយទ្រទ្រង់ខាងហិរញ្ញវត្ថុ បើពិនិត្យឃើញថា មានប្រយោជន៍ដល់ការងារកំចាត់ជំងឺរបេង ។

មាត្រា ៦ :គណៈកម្មការជាតិកំចាត់ជំងឺរបេង អាចសហការជាមួយអង្គការក្រៅរដ្ឋាភិបាលនានា ដែលបាន និងកំពុងជួយទ្រទ្រង់យ៉ាងសកម្មដល់ការងាររបេងជាមួយកម្មវិធីជាតិជំងឺរបេង ។

មាត្រា ៧: គណៈកម្មការជាតិកំចាត់ជំងឺរបេង មានទីស្នាក់ការអចិន្ត្រៃយ៍នៅក្រសួងសុខាភិបាល ហើយមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសុខាភិបាល ។

មាត្រា ៨ :សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសុខាភិបាល សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ អភិបាលខេត្ត ក្រុង និងឯកឧត្តម អស់លោក លោកស្រី ដែលមានចែងក្នុងមាត្រា ១ ២ និង ៨ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពី

ថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៧១ អនក្រ.បក

ស្តីពី

ការបង្កើតគណៈកម្មការជាតិ សំរាប់បង្ការទប់ស្កាត់

និង បន្ថយជំងឺអេដស៍ និង ជំងឺកាមរោគ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ។
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាកសត្រ នៃព្រះរាជាណាចក្រកមសុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល ។
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សំរេច

មាត្រា ១ : បង្កើតគណៈកម្មការជាតិមួយឈ្មោះថា គណៈកម្មការជាតិសំរាប់បង្ការទប់ស្កាត់ និងបន្ថយជំងឺអេដស៍ និងជំងឺកាមរោគ ដែលមានសមាសភាពដូចខាងក្រោម :

១- សម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី ១ ប្រធានកិត្តិយស
២- ឯកឧត្តម **ឈា ថាំង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រធាន
៣- ឯកឧត្តម រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន
៤- ឯកឧត្តម រដ្ឋលេខាធិការក្រសួងពត៌មាន សមាជិក
៥- ឯកឧត្តម រដ្ឋលេខាធិការក្រសួងអប់រំ សមាជិក
៦- ឯកឧត្តម រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានកិច្ចការនារី សមាជិក
៧- ឯកឧត្តម អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក
៨- លោក អភិបាលរងរាជធានីភ្នំពេញ និង ខេត្ត ក្រុង សមាជិក

មាត្រា ២ : គណៈកម្មការជាតិ សំរាប់បង្ការទប់ស្កាត់ និងបន្ថយជំងឺអេដស៍ និងជំងឺកាមរោគមានលេខាធិការដ្ឋានជាជំនួយការ ដែលមានសមាសភាពដូចខាងក្រោម :

១- លោក វេជ្ជបណ្ឌិត **ហ៊ុន ឈុនលី** ប្រធានលេខាធិការដ្ឋាន
២- លោក តំណាងក្រសួងមហាផ្ទៃ អនុប្រធាន
៣- លោក តំណាងក្រសួងអប់រំ សមាជិក
៤- លោក តំណាងក្រសួងពត៌មាន សមាជិក
៥- លោក តំណាងក្រសួងទេសចរណ៍ សមាជិក
៦- លោកស្រី តំណាងរដ្ឋលេខាធិការដ្ឋានកិច្ចការនារី សមាជិក
៧- លោកវេជ្ជបណ្ឌិត **ហោ ម៉ុនឡេង** មន្ត្រីក្រសួងសុខាភិបាល សមាជិក

មាត្រា ៣ :គណៈកម្មការជាតិ សំរាប់បង្ការទប់ស្កាត់ និងបន្ថយជំងឺអេដស៍ និងជំងឺកាមរោគមានភារកិច្ច :

- ទទួលខុសត្រូវរួមលើវិធានការការពារ និងព្យាបាល ទប់ស្កាត់ការរីករាលដាលនៃជំងឺអេដស៍ និងជំងឺកាមរោគ ។
- ទទួលខុសត្រូវពិនិត្យស្រាវជ្រាវជំងឺអេដស៍ ជំងឺកាមរោគ និងធ្វើស្ថិតិមេបនពេស្យា

និងស្ត្រីពេស្យា ក្នុងព្រះរាជាណាចក្រកម្ពុជា ។

- លើកយោបល់ជូនរាជរដ្ឋាភិបាលកម្ពុជាអំពីបញ្ហាទាំងឡាយដែលទាក់ទង និងសភាព-ការណ៍ជំងឺអេដស៍ ជំងឺកាមរោគ ពេស្យាចារ និងមេបនពេស្យា ។
- ផ្តល់យោបល់ណែនាំដល់មន្ទីរពិសោធន៍ និងមន្ទីរពេទ្យដែលទទួលព្យាបាល ថែទាំអ្នកផ្ទុកមេរោគ អេច-អៃ-វី ឬអ្នកកើតជំងឺអេដស៍ និងអ្នកកើតជំងឺកាមរោគ ។
- ទទួលខុសត្រូវរៀបចំច្បាប់ និងលិខិតបទដ្ឋានស្តីពីការបង្ការ ទប់ស្កាត់ និង បន្ថយជំងឺអេដស៍ និងសកម្មភាពពេស្យាចារ ។
- ពិនិត្យ អនុម័ត លើគំរោងកម្មវិធីអប់រំ ដែលត្រូវធ្វើការផ្សព្វផ្សាយ នៅតាមសាលារៀនតាមក្រសួងស្ថាប័ននានា តាមវិទ្យុ និងទូរទស្សន៍ និង លើកម្មវិធីអប់រំស្ត្រីពេស្យាដោយផ្ទាល់ ។
- ជំរុញការអនុវត្តន៍នូវបណ្តាវិធានការទាំងឡាយដែលរាជរដ្ឋាភិបាលបានដាក់ចុះ ។

លេខាធិការដ្ឋានមានភារកិច្ច :

- ផ្តល់ពត៌មានអំពីសកម្មភាពនៃការអនុវត្តន៍ការងារបង្ការ ទប់ស្កាត់ និងបន្ថយជំងឺអេដស៍ និង ជំងឺកាមរោគតាមកាលកំណត់ជូនគណៈកម្មការជាតិនេះ ។
- រៀបចំខ្លឹមសារ រូបភាពសំរាប់ផ្សព្វផ្សាយតាមវិទ្យុ-ទូរទស្សន៍ អោយបានទៀងទាត់ និងសមស្របតាមប្រពៃណីជាតិ ជៀសវាងរូបអាសអាភាស ។
- រៀបចំខ្លឹមសារ និងរូបភាពសំរាប់បញ្ចូលក្នុងកម្មវិធីសិក្សានានា និង សំរាប់ផ្សព្វផ្សាយតាមក្រសួងស្ថាប័ន អោយស្របតាមប្រពៃណីជាតិ ។ ចំពោះបនពេស្យាត្រូវអនុវត្តដោយឡែក ។
- ទទួលខុសត្រូវក្នុងការតាមដាន និងអនុវត្តនូវសកម្មភាពទាំងឡាយក្នុងកម្មវិធីបង្ការទប់ស្កាត់ និងបន្ថយជំងឺអេដស៍ និង ជំងឺកាមរោគ តាមដំណាក់កាលនីមួយ ៗ ។
- សហការជាមួយក្រសួងមានសមត្ថកិច្ចក្នុងការបង្ក្រាបមេបន និងអប់រំពេស្យាចារ ។
- លើកកម្មវិធីរយៈពេលខ្លី មធ្យម វែង ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺអេដស៍ និងជំងឺកាមរោគ និងលើកគំរោងថវិកាសំរាប់ចំណាយក្នុងការងារនេះ ។
- សហការយ៉ាងជិតស្និទ្ធជាមួយអង្គការសុខភាពពិភពលោក និងអង្គការអន្តរជាតិនានា

ដើម្បីទាក់ទងសុំជំនួយឧបត្ថម្ភថវិកា ឧបករណ៍ សំភារៈ សំរាប់បំរើការងារនេះអោយដំណើរការបានជាប់ជាប្រចាំ ។

- ធ្វើរបាយការណ៍អោយបានទៀងទាត់រៀងរាល់ដំណាច់ខែជូនរាជរដ្ឋាភិបាល ស្តីពីសភាពការណ៍វិវឌ្ឍន៍ និងការរីកចំរើននៃសកម្មភាពរបស់គណៈកម្មការជាតិនេះ ។

មាត្រា ៤ : គណៈកម្មការជាតិ សំរាប់បង្ការទប់ស្កាត់ និងបន្ថយជំងឺ អេដស៍ និងជំងឺកាមរោគ មានទីស្នាក់ការអចិន្ត្រៃយ៍នៅក្រសួងសុខាភិបាល និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសុខាភិបាល ។

មាត្រា ៥ : សេចក្តីសំរេចលេខ ៣៦ សសរ ចុះថ្ងៃទី ១១-១២-៩៣ និង បទបញ្ញត្តិទាំងឡាយដែលផ្ទុយពីខ្លឹមសារនៃអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋលេខាធិការដ្ឋានកិច្ចការនារី ក្រសួងទេសចរណ៍ ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ អភិបាល ខេត្ត-ក្រុង និងឯកឧត្តម អស់លោក លោកស្រី ដែលមានចែងក្នុងមាត្រា ១ ២ និង ៦ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៧២ អនក្រ.បក

ស្តីពី

ការកែសំរួលនាយកដ្ឋានធារាសាស្ត្រ ឧតុនិយមនិងជលសាស្ត្រ

ឱ្យទៅជា អគ្គនាយកដ្ឋានធារាសាស្ត្រឧតុនិយមនិងជលសាស្ត្រ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើតាមព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សំរេច

មាត្រា ១ : ត្រូវបានកែសំរួល ពីនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និងជលសាស្ត្រ ឱយទៅជាអគ្គនាយក ដ្ឋានធារាសាស្ត្រឧតុនិយម និងជលសាស្ត្រ មានទីតាំងនៅរាជធានីភ្នំពេញ និងស្ថិតនៅក្រោម ការគ្រប់គ្រង និងដឹកនាំផ្ទាល់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា ២ : អគ្គនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និងជលសាស្ត្រ មានភារកិច្ចសំខាន់ៗ ដូចខាងក្រោម ÷

- រៀបចំគោលនយោបាយ គោលការណ៍ និងលិខិតបទដ្ឋាន ដែលពាក់ព័ន្ធដល់ធនធានទឹក ទាំងលើដី ទាំងក្រោមដី ដើម្បីធ្វើអាជីវកម្មក្នុងការប្រើប្រាស់ទឹក បំរើឱយដល់ការដាំដុះ និងជីវភាពប្រជារាស្ត្រដោយប្រសិទ្ធខ្ពស់ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។
- សិក្សាស្រាវជ្រាវ វាយតំលៃកំណត់នូវទិសដៅកម្មវិធីស្តារ និងអភិវឌ្ឍន៍វិស័យធារាសាស្ត្រ ឧតុនិយម និងជលសាស្ត្រក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។
- ចាត់តាំងព្យាករណ៍ ឧតុនិយម និងជលសាស្ត្រ រយៈពេលវែង ខ្លី សំដៅបំរើអោយគ្រប់វិស័យ និងជូនដំណឹងជាមុននូវគ្រោះធម្មជាតិដែលអាចកើតមានឡើង ដើម្បីមានវិធាន

ការអន្តរាគមន៍ទាន់ពេលវេលា ។

-ប្រមូលចងក្រងឯកសារ និងធ្វើអាជីវកម្ម នូវទិន្នន័យ ឧតុនិយម និងជលសាស្ត្រ បំរើអោយវិស័យនានាដែលមានការពាក់ព័ន្ធជាលក្ខណៈជាតិ និងអន្តរជាតិ ។

-ស្រាវជ្រាវ បច្ចេកទេសវិទ្យាសាស្ត្រ ដើម្បីមានវិធានការកែលំអ ផ្សព្វផ្សាយ និងបណ្តុះបណ្តាល ។

-ពង្រឹង និងពង្រីកកិច្ចសហការជាតិ និងការងារសហប្រតិបត្តិការអន្តរជាតិលើវិស័យធារាសាស្ត្រ ឧតុនិយម និងជលសាស្ត្រ ។

មាត្រា ៣ : រចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និងជលសាស្ត្រមាន :

១-នាយកដ្ឋានរដ្ឋបាល-ផែនការ-ហិរញ្ញវត្ថុ

២-នាយកដ្ឋានស្រាវជ្រាវ និងផ្សព្វផ្សាយ

៣-នាយកដ្ឋានគ្រប់គ្រងទឹក

៤-នាយកដ្ឋានវិស្វកម្ម

៥-នាយកដ្ឋានជលសាស្ត្រ

៦-នាយកដ្ឋានឧតុនិយម

មាត្រា ៤ : អគ្គនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និងជលសាស្ត្រ ដឹកនាំដោយអគ្គនាយកមួយរូប និងអគ្គនាយករងមួយចំនួន ជាជំនួយការ ។

មាត្រា ៥ : ក្របខ័ណ្ឌរបស់អគ្គនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និងជលសាស្ត្រ អាស្រ័យដោយរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទកំណត់សំរេច ។

មាត្រា ៦ : បទបញ្ញត្តិទាំងឡាយណាដែលមានពីមុនហើយផ្ទុយ នឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៧ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ស្ថាប័នមានការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗ ខ្លួន ។

មាត្រា ៨ : អនុក្រឹត្យនេះ មានអានុភាពគតិយុត្ត ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និងត្រា
ហ៊ុន សែន

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩

អនុក្រឹត្យលេខ ១០៩ អនក្រ គត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតនិងប្រើប្រាស់មេដាយស្ថាបនាជាតិ និងប័ណ្ណស្ថាបនាជាតិ
- តាមសំណើរបស់សាលាក្រុងភ្នំពេញ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់លេខ ៣ ចំពោះក្រុមហ៊ុន **ឈាំ សាន**

ដែលបាន ឧបត្ថម្ភប្រាក់ចំនួន ២.១១៤ ដុល្លារអាមេរិក សំរាប់ធ្វើស៊ុមដាំដើមឈើ ដើម្បីកែលំអសោភ័ណភាពរាជធានីភ្នំពេញ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងប្រតិភូរាជរដ្ឋាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្ថលេខា និងត្រា ហត្ថលេខា និងត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១១០ អនក្រ គត

ស្ដីពីការជូនមេដាយស្ថាបនាជាតិ

****

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្ដីពីការបង្កើតនិងប្រើប្រាស់មេដាយស្ថាបនាជាតិ

និងបណ្ណស្ថាបនាជាតិ

–តាមសំណើរបស់ក្រសួងអប់រំយុវជននិងកីឡា

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់លេខ ២ ចំពោះសប្បុរសជន ២រូបដែលបាន ឧបត្ថម្ភប្រាក់កសាងសាលាបឋមសិក្សាម៉ក់វ៉ាច នៅឃុំរក្សជ័យ ស្រុកបាភ្នំ ខេត្តព្រៃវែង ដូចមានរាយ នាមខាងក្រោម ÷

១–ឧបាសិកា **ខម ពាញ** ឧបត្ថម្ភប្រាក់ចំនួន ៦.០០០ ដុល្លារអាមេរិក

២–លោក **ម៉ក់ ទ័ន** ឧបត្ថម្ភប្រាក់ចំនួន ៥.០៤៨,៥៨ ដុល្លារអាមេរិក

មាត្រា ២ :សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាល ខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខា តទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * * *

II-**ការងារបណ្តាក្រសួង**

១_ទីស្តីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៣២ សហវ. ប្រក.ប

ស្តីពី
ការកែតម្រូវ ការដាក់មន្ត្រីរាជការចូលនិវត្តន៍
០២ រូប ដោយអនុញ្ញាតអោយបន្តការងារវិញ

******

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញប្រកាសលេខ ០៨១ សហវ.ប្រក.ប ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការ[illegible]រាជការក្របខ័ណ្ឌចូលនិវត្តន៍ និង ចូលបាត់បង់សមត្ថភាពពលកម្ម
- បានពិនិត្យសំណើលេខ ២០២ សហវ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់មន្ទីរ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តតាកែវ
- បានពិនិត្យសំណើលេខ ០៤០ សហវ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៥ របស់មន្ទីរ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តកណ្តាល
- តាមសំណើ របស់នាយកដ្ឋានបុគ្គលិក

សំរេច

មាត្រា ១ :កែតំរូវការដាក់អោយមន្ត្រីរាជការចូលនិវត្តន៍ ០២ រូប ដូចមានរាយនាមខាងក្រោម ដោយអនុញ្ញាតអោយបន្តការងារវិញ « មូលហេតុដោយសារការវាយអង្គុលីលេខមានការភ័ន្តច្រឡំ ឆ្នាំកំណើតក្នុងតារាងស្ថិតិរបស់មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខេត្ត » :

១- លោក **វ័ន្ត ឆែម** មន្ត្រី មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខេត្តតាកែវ « កែតំរូវឆ្នាំកំណើតពី ឆ្នាំ ១៩៣៩ មកថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៤៥ »

២- លោក **យី សុខ** មន្ត្រី មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខេត្តកណ្តាល « កែតំរូវឆ្នាំកំណើតពី ឆ្នាំ ១៩៣៨ មកថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ១៩៤៨ »

មាត្រា ២ : នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានថវិការដ្ឋ ប្រធានមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្តតាកែវ-កណ្តាល និង អង្គភាពពាក់ព័ន្ធព្រម ទាំងសាម៉ីខ្លួន ដូចក្នុងមាត្រា ០១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

គាត ឈន់

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាស ៣២៨ ប្រក សហវ.ថ

ស្តីពីការបង្វែរឥណទាន

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០១ នស ៩៣. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ១០ នស ៩៤. ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ០៩ អនក្រ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ ស្តីអំពីការបែងចែកឥណទាន ផ្ទៃក្នុងតាមជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ជូនបណ្តាក្រសួងតាមឥណទានចែងក្នុងច្បាប់ហិរញ្ញវត្ថុសំរាប់ ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុលេខ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកា ឆ្នាំ ១៩៩៥
- តាមសំណើរបស់ ក្រសួងពតិមាន លេខ ៧៩៥/៩៥ ពម. ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : ត្រូវបានប្រតិបត្តិនៅក្នុងរង្វង់ថវិកា របស់ក្រសួងពតិមាន សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ នូវការបង្វែរឥណទានដូចបានបញ្ជាក់ខាងក្រោមនេះ :

ឯកតាពាន់រៀ

ជំពូក	ប្រការ	កថាខ័ណ្ឌ	វាក្យខ័ណ្ឌ	ចំណាត់ថ្នាក់ចំណាយ	ស្ថានភាពឥណទានដើមឆ្នាំ	ការកែប្រែឥណទាន		ស្ថានភាពឥណទានថ្មី
						កើន	ថយ	
				ការបង្វែរពីជំពូក ១១			៤.០០០	
១១	០១	០១	០២	ការរៀបចំ និងថែទាំ	១០៨.៧៥១	–	៤.០០០	១០៤.៧៥
				ផលប្រយោជន៍ជំពូក ១១		៤.០០០		
១១	០១	០២		ចលនវត្ថុ និងសំភារៈ	១៨.២៤៩	៤.០០០	–	២២.២៤

ប្រការ ២ : ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងពតិមាន ត្រូវទទួលបន្ទុកក្នុងការអនុវត្តន៍ ប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

អនុរដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

នាយ ថន

* * * *

២_ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

ប្រកាស

ភ្នំពេញ ,ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៥០៧ អយក.ប្រក

ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សាមិត្តភាពមកជា

សាលាបឋមសិក្សា « សម្តេច ជាស៊ីម »

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០–១១–១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ
- បានពិនិត្យលិខិតស្នើសុំរបស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត កោះកុង លេខ ១៦៧ អយក.ខកក ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៥
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

សម្រេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជន និង កីឡា ខេត្តកោះកុង ប្តូរឈ្មោះសាលាបឋមសិក្សាមិត្តភាព មកជាសាលាបឋមសិក្សា « **សម្តេចជាស៊ីម** » វិញចាប់ពីឆ្នាំសិក្សា ១៩៩៥–១៩៩៦ នេះតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍

ប្រការ ៣ : ប្រធានមន្ទីរ ក្រសួងអប់រំ យុវជន និង កីឡា ប្រធាននាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចាត់តាំង

ប្រធានមន្ទីរអប់រំ យុវជន និង កីឡាខេត្តកោះកុង សាលាបឋមសិក្សាសម្តេច ជា ស៊ីម មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
តុល ឡោះ

* * * *

៣_ទីស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៦២ ប្រក.វវស.ចុ

ស្តីពី

ការលុបឈ្មោះមន្ត្រីរាជការ មន្ទីរ
វប្បធម៌ និង វិចិត្រសិល្បៈ ខេត្តកណ្តាល

******

រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

–បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
–បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
–យោងតាមសំណើសុំលុបឈ្មោះ លេខ ១៤៧ សរវស ចុះថ្ងៃទី ១០–៨–៩៥ របស់មន្ទីរ វប្បធម៌ និង វិចិត្រសិល្បៈខេត្តកណ្តាល

-យោងតាមចំណារយល់ព្រមពីថ្នាក់ដឹកនាំក្រសួងចុះថ្ងៃទី ១១-៩-៩៥

មាត្រា ១ : មន្ត្រីរាជការមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្តកណ្តាលចំនួន ០២ «ពីរ» នាក់ដូចមាន រាយនាមខាងក្រោមនេះ ត្រូវបានអនុញ្ញាតអោយលុបឈ្មោះចេញពីបញ្ជីក្របខ័ណ្ឌ មន្ត្រីរាជការ មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្តកណ្តាល ចាប់ពីថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ដោយសុំលាឈប់ពីការងារនិងបានទទួលរបបឧបត្ថម្ភគោលនយោបាយ តាមការកំណត់របស់រាជរដ្ឋាភិបាល :

១- លោក **ថា នុង្ស៊ី** បុគ្គលិក

២- អ្នកស្រី **ជ័យ សុផល** បុគ្គលិកការិយាល័យវប្បធម៌ស្រុក

មាត្រា ២ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្តកណ្តាល ព្រមទាំង សាម៉ីខ្លួនមានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ព្រះហស្តលេខា និងត្រា

ស៊ីសុវត្ថិ ស៊ីរីវុធ ប៉ាណារ៉ា

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាសលេខ : លេខ ១៦៣ ប្រក.វវស.ប្ក

ស្តីពី

ការលុបឈ្មោះមន្ត្រីរាជការមន្ទីរ

វប្បធម៌ និង វិចិត្រសិល្បៈ ខេត្តព្រៃវែង

==========

រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា ។
- យោងតាមសំណើសុំលុបឈ្មោះលេខ ២២១–៩៥ ចុះថ្ងៃទី ១៧–៧–៩៥ លេខ ២៤៣– ៩៥ និងលេខ ២៤៤– ៩៥ ចុះថ្ងៃទី ២៨–៨–៩៥ របស់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្ត ព្រៃវែង ។
- យោងតាមចំណារយល់ព្រមពីថ្នាក់ដឹកនាំក្រសួងចុះថ្ងៃទី១១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ។

សំរេច

មាត្រា ១ : មន្ត្រីរាជការមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តព្រៃវែង ចំនួន ០៣ រូប នាកដូចមានរាយនាមខាងក្រោមនេះត្រូវបានអនុញ្ញាតអោយលុបឈ្មោះចេញពីបញ្ជីក្របខ័ណ្ឌ មន្ត្រីរាជការ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រៃវែង ចាប់ពីថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ដោយសុំលាឈប់ពីការងារ និងបានទទួលរបបឧបត្ថម្ភ[illegible]ចាយតាមការកំណត់របស់រាជរដ្ឋាភិបាល ។

១– លោក កែន សុណា អនុប្រធានការិយាល័យវប្បធម៌ស្រុក[illegible]

២– លោក ម៉ែន គី បុគ្គលិក

៣– លោក ម៉ែន ប៊ុនរ៉ែន អនុប្រធានការិយាល័យសិល្បៈ

មាត្រា ២ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តព្រៃវែង ព្រមទាំងសាមីខ្លួន មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ព្រះហស្តលេខា និងត្រា

ស៊ីសុវត្ថិ ស៊ីរីវុឌ្ឍ ប៉ាណារ៉ា

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ១៦៤ ប្រក.វវស.បុ

ស្តីពីការបញ្ចូលក្របខ័ណ្ឌមន្ត្រីរាជការ

នៅមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តកំពង់ស្ពឺ

==========

រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម **សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- យោងប្រកាសលេខ ២៣៧.៩៥ ពម.ប្រក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៩៥ របស់ក្រសួងពតិមាន ។

សម្រេច

ប្រការ ១ : ត្រូវបានបញ្ចូលលោក **ឡឹក នាង** អនុប្រធានមន្ទីរពតិមានខេត្តកំពង់ស្ពឺ ក្នុងក្របខ័ណ្ឌរដ្ឋបាលមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តកំពង់ស្ពឺ ឋានៈជាអនុប្រធានមន្ទីរក្រោមឱវាទក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

ប្រការ ២ : បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ ត្រូវបានបើកនៅអង្គភាពថ្មីបន្ទាប់ពីអង្គភាពដើមបានចេញវិញ្ញាបនប័ត្រផ្តាច់បៀវត្ស ។

ប្រការ ៣ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តកំពង់ស្ពឺ និង

លោក ឡឹក នាង មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ
ព្រះហស្ថលេខា និងត្រា
ស៊ីសុវត្ថិ ស៊ីរីវុធ ឃាំណារ៉ា

* * * *

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១៦៥ ប្រក.វធស.ប្ន

ស្តីពី

ការលុបឈ្មោះមន្ត្រីរាជការ មន្ទីរវប្បធម៌

និងវិចិត្រសិល្បៈខេត្តកណ្តាល

==========

រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា ។
- យោងតាមសំណើសុំលុបឈ្មោះ លេខ ១៤៦ សនវវស.ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៥ របស់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកណ្តាល ។

សំរេច

ប្រការ ១ : លោក នូ សាវុធ បុគ្គលិកការិយាល័យវប្បធម៌ស្រុកលើកដែក នៃមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តកណ្តាល ត្រូវបានអនុញ្ញាតអោយលុបឈ្មោះចេញពីបញ្ជីក្របខ័ណ្ឌមន្ត្រីរាជការមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកណ្តាល ចាប់ពីថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ដោយបោះបង់ចោលការងារ ។

ប្រការ ២ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល និងមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកណ្ដាល មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
នុត ណារ៉ាង

៤_ទីស្តីការក្រសួងធម្មការ និងសាសនា

ប្រកាស

ភ្នំពេញ,ថ្ងៃទី ២៨ ខែ កញ្ញ ឆ្នាំ ១៩៩៥

ប្រកាស លេខ ១៩៤ / ៩៥ កធស.ប្រក

ស្តីពីការលុបឈ្មោះ មន្ត្រី រាជការ

===========

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩២
- បានឃើញច្បាប់ ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ដែលប្រកាស អោយប្រើតាមក្រឹត្យលេខ ១៧ ក្រ ចុះថ្ងៃទី ០៨ កុម្ភៈ ១៩៩២
- បានឃើញអនុក្រឹត្យលេខ.២២ អនក្រ ចុះថ្ងៃទី ៣០ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃក្រសួងធម្មការ និងសាសនា
- បានឃើញពាក្យស្នើសុំលាឈប់ពីការងាររបស់លោក **ពុត សំកុល** ចុះថ្ងៃទី ២៨ ខែ កក្កដា ១៩៩៥ និងពាក្យស្នើសុំលាឈប់ពីការងាររបស់អ្នកស្រី **ខឹម ចាន់ធី** ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥
- បានឃើញលិខិតលេខ ១៩៥–៩៥ ធសខ ចុះថ្ងៃទី ០៨ សីហា ១៩៩៥ របស់មន្ទីរ

ធម្មការ និងសាសនា ខេត្តស្ទឹងត្រែង ។

សំរេច

ប្រការ ១ : លុបឈ្មោះលោក **ពុត សំកុល** និងអ្នកស្រី **ខឹម ផាន់នី** ចេញពីក្របខ័ណ្ឌមន្ទីរធម្មការ និង សាសនា ខេត្តស្ទឹងត្រែង ។

ប្រការ ២ : បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ របស់លោក **ពុត សំកុល** និងអ្នកស្រី **ខឹម ផាន់នី** ត្រូវផ្តាច់ ចាប់ពីថ្ងៃទី ០១ ខែ តុលា ១៩៩៥ ទៅ ។

ប្រការ ៣ : មន្ទីរធម្មការ និងសាសនាខេត្ត មន្ទីរផែនការ មន្ទីរហិរញ្ញវត្ថុខេត្តស្ទឹងត្រែង និង សាមីខ្លួន ដែលមានឈ្មោះក្នុងប្រការមួយត្រូវអនុវត្តរៀងៗខ្លួន តាមសេចក្តីប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ឃឿន ចន្ទរ័ត្ន

* * * *

ភ្នំពេញ ,ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាស លេខ ១៩៥ / ៩៥ កធស.ប្រក

ស្តីពីការលុបឈ្មោះមន្ត្រីរាជការ

=========

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១-១១-៩៣
- បានឃើញច្បាប់ ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនាដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ១៧ ក្រ ចុះថ្ងៃទី ០៨ កុម្ភៈ ១៩៩២
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ មិថុនា ១៩៩២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃក្រសួងធម្មការ និងសាសនា

- បានឃើញលិខិតលេខ ៥០–៩៥ មធ ចុះថ្ងៃទី ១០ ខែ កក្កដា ១៩៩៥ របស់មន្ទីរធម្មការ និងសាសនា ខេត្តព្រះវិហារ ។

សំរេច

ប្រការ ១ : លុបឈ្មោះ **ឈោរ សារុណា** ចេញពីក្របខ័ណ្ឌមន្ទីរធម្មការ និងសាសនាខេត្តព្រះវិហារ

ប្រការ ២ : បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ របស់លោក **ឈោរ សារុណា** ចាប់ផ្តាច់ពីថ្ងៃទី ០១ ខែ តុលា ១៩៩៥ ទៅ ។

ប្រការ ៣ : មន្ទីរធម្មការ និងសាសនាខេត្ត មន្ទីរហិរញ្ញវត្ថុ ខេត្ត ព្រះវិហារ និងសាម៉ីខ្លួន ត្រូវអនុវត្តរៀងៗ ខ្លួនតាមប្រកាសនេះ ។

ប្រការ ៤ : សេចក្តីប្រកាសនេះ មានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ហឿន ចន្ទ្រាវុធ

* * * *

ភ្នំពេញ,ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ២០០/ ៩៥ កធស

ស្តីពីការទទួលស្គាល់គណៈកម្មាធិការប្រិយសម្ព័ន្ធគ្រិស្តបរិសទ័នៅកម្ពុជា

==========

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម **សីហនុវរ្ម័ន**

ព្រះចៅ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងទី២របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះចៅ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ នៃរាជរដ្ឋាភិបាលរបស់ព្រះរាជាចក្រកម្ពុជា ។
- យោងអង្គប្រជុំពិភាក្សាតំណាងគ្រិស្តបរិសទ័ ដែលប្រព្រឹត្តទៅនៅក្រសួងធម្មការ និងសាសនា នាថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ១៩៩៥ ។
- បានឃើញលិខិតស្នើទទួលស្គាល់របស់គណៈកម្មាធិការ ប្រិយសម្ព័ន្ធគ្រិស្តកម្ពុជា ចុះថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ១៩៩៥ ។

សំរេច

ប្រការ ១ : ទទួលស្គាល់ « គណៈកម្មាធិការប្រិយសម្ព័ន្ធ គ្រិស្តបរិស័ទកម្ពុជា » ជាផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ២ : « គណៈកម្មាធិការប្រិយសម្ព័ន្ធ គ្រិស្តបរិសទ័កម្ពុជា » ត្រូវគោរពតាមលក្ខន្តិកៈរបស់គណៈកម្មាធិការប្រិយសម្ព័ន្ធ គ្រិស្តបរិស័ទកម្ពុជា ដែលមានតំកល់ទុកនៅក្រសួង រាល់ការកែប្រែលក្ខន្តិកៈថ្មី ត្រូវមានការឯកភាពពីក្រសួង ។

ប្រការ ៣ : «គណៈកម្មាធិការប្រិយសម្ព័ន្ធ គ្រិស្តបរិសទ័កម្ពុជា » ត្រូវសហការអោយបានល្អជាមួយអង្គភាពពាក់ព័ន្ធករណីមានការ ផ្លាស់ប្តូរសមាសភាពដឹកនាំត្រូវមានការជូនដំណឹងមកក្រសួង ។

ប្រការ ៤ : « គណៈកម្មាធិការប្រិយសម្ព័ន្ធ គ្រិស្តបរិសទ័កម្ពុជា » ត្រូវគោរពអោយបានម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាក្រកម្ពុជា និងបទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និង សាសនា រក្សាអោយបាននូវសណ្តាប់ធ្នាប់ និងរបៀបរៀបរយសង្គម ។

ប្រការ ៥ : រាល់ការអនុវត្តផ្ទុយពីសេចក្តីម្រេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៦: នាយកដ្ឋានសាសនា និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលមានការពាក់ព័ន្ធត្រូវ សហការអនុវត្តន៍សេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ។

ប្រការ ៧ : សេចក្តីរេចនេះមានអនុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ
ហត្ថលេខា និងត្រា
ហៀង ឧត្តរ័ត្ន

* * * *

៥_រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ប្រកាស

ភ្នំពេញ .ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាស ១០០២ មស.ចល

ស្តីពីការបញ្ចូលក្របខ័ណ្ឌពេញសិទ្ធិ

****

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ ស.រកត ១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ

១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញការបញ្ចប់កម្មសិក្សាសាកល្បងរបស់មន្ត្រីរាជការ នៃរដ្ឋលេខាធិការដ្ឋានមុខងារ សាធារណៈ ចុះថ្ងៃទី ៣១.៧.៩៥ ។

សំរេច

ប្រការ ១ : បញ្ចូលក្របខ័ណ្ឌពេញសិទ្ធិដល់មន្ត្រីរាជការ ដែលបានបញ្ចប់កម្មសិក្សាដូចមានរាយនាមខាងក្រោមនេះ ។

១- លោក **ចាន់ ចាន់ដេ** បំរើការងារនៅនាយកដ្ឋានក្របខ័ណ្ឌ

២- កញ្ញា **តាំង មុំ** បំរើការងារនៅនាយកដ្ឋានក្របខ័ណ្ឌ

ប្រការ ២ : មន្ត្រីរាជការដូចមានក្នុងប្រការ ១ត្រូវទទួលកាំប្រាក់បៀវត្ស ខ.II.១ស្មើ ២៧.០០០៛០០ ។

ប្រការ ៣ : ខុទ្ទកាល័យ នាយកដ្ឋានបៀវត្ស នាយកដ្ឋានក្របខ័ណ្ឌ និងសាមីខ្លួនមានភារកិច្ចអនុវត្តប្រកាសនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
ប្រាក់ សុខ

* * *

៦_រដ្ឋលេខាធិការដ្ឋានកិច្ចការនារី

ប្រកាស

ភ្នំពេញ,ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៩៥

ប្រកាស លេខ ៨៣៨ អកន

ស្តីពីការផ្ទេរមន្ត្រីរាជការ

រដ្ឋលេខាធិការកិច្ចការនារី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញសំណើរបស់សាមីខ្លួន ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៥ ។

សំរេច

ប្រការ ១ : ផ្ទេរអ្នកស្រី **សំ គឹមឡៀន** អោយទៅបំរើការងារនៅមន្ទីរកិច្ចការនារីខេត្តកោះកុង ។

ប្រការ ២ : ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ ទៀតរបស់សាមីខ្លួន ត្រូវបានអនុវត្តនៅអង្គភាពថ្មីបន្ទាប់ពីបានទទួលការផ្តាច់ប្រាក់ ពីរដ្ឋលេខាធិការដ្ឋានកិច្ចការនារី ។

ប្រការ ៣ : លោកស្រីអគ្គនាយករដ្ឋបាល-ផែនការ លោកស្រីអគ្គនាយកកម្មវិធី នាយកខុទ្ទកាល័យ នាយកហិរញ្ញកិច្ចនិងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារ នៃប្រកាសនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃដែលចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

គៀត សុគន្ធ

បោះពុម្ពនៅរោងពុម្ពទីស្ដីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ៥៣២ រៀល.